# ពិភាក្សាការងាររបស់ ឯកឧត្តមទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ ជាមួយ ឯកឧត្តមអគ្គនាយកអង្គការពាណិជ្ជកម្មពិភពលោក

នៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៩ ឯកឧត្តមបណ្ឌិត **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម បានអនុញ្ញាតឱ្យ ឯកឧត្តម **ប៉ាស្កាល់ ឡាមី** អគ្គនាយកអង្គការពាណិជ្ជកម្មពិភពលោក សំដែងការគួរសម និងពិភាក្សាការងារ ក្នុងដំណើរទស្សនកិច្ចមកកាន់ប្រទេសកម្ពុជា ដើម្បីមកចូលរួមកិច្ចប្រជុំតំបន់ស្តីពី វិបត្តិហិរញ្ញវត្ថុពិភពលោក ការរីកលូតលាស់ផ្នែកលើការនាំចេញ និងជំនួយសំរាប់ពាណិជ្ជកម្ម សំរាប់តំបន់អាស៊ី និងប៉ាស៊ីភិច ពីថ្ងៃទី២៨-២៩ ខែឧសភា ឆ្នាំ២០០៩ នៅឯសណ្ឋាគារ អង្គរផាឡេស រីហ្សិត និងស្ប៉ា នៅទីក្រុងសៀមរាប ។

ជាកិច្ចចាប់ផ្តើម ឯកឧត្តមបណ្ឌិតទេសរដ្ឋមន្ត្រី បានសំដែងនូវការស្វាគមន៍យ៉ាងកក់ក្តៅ ចំពោះការអញ្ជើញមក ទស្សនកិច្ចជាលើកទី២ របស់ឯកឧត្តមអគ្គនាយកអង្គការពាណិជ្ជកម្មពិភពលោក នៅព្រះរាជាណាចក្រកម្ពុជា និងបានពាំនាំនូវការផ្តាំផ្ញើសួរសុខទុក្ខពីសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។ ឯកឧត្តមបណ្ឌិតទេសរដ្ឋមន្ត្រី ក៏បានជំរាបលោកអគ្គនាយកពាណិជ្ជកម្មពិភពលោកផងដែរ អំពីសភាពការណ៍ និងការរីកចំរើនថ្មីៗ នៅកម្ពុជាបន្ទាប់ពីការធ្វើទស្សនកិច្ចលើកទី១ របស់ឯកឧត្តមអគ្គនាយក ដើម្បីចូលរួមសន្និសីទថ្នាក់រដ្ឋមន្ត្រី របស់ប្រទេសអភិវឌ្ឍន៍តិចតួច នៅទីក្រុងសៀមរាប កាលពីខែវិច្ឆិកា ឆ្នាំ២០០៨ កន្លងទៅ ។

បន្ទាប់មក ភាគីទាំងពីរបានធ្វើការផ្លាស់ប្តូរមតិលើរបៀបវារៈនៃការចរចាទីក្រុងដូហា របស់អង្គការពាណិជ្ជកម្មពិភពលោក និងរិះរកនូវវិធីដើម្បីពន្លឿនកិច្ចរចរចា។ ចំពោះបញ្ហានេះ ឯកឧត្តមបណ្ឌិតទេសរដ្ឋមន្ត្រីបានបញ្ជាក់ជាថ្មីនូវជំហររបស់ រាជរដ្ឋាភិបាលកម្ពុជាថា ក្នុងនាមជាប្រទេសនាំមុខនៅក្នុងចំណោមប្រទេសអភិវឌ្ឍន៍តិចតួច កម្ពុជាគាំទ្រយ៉ាងខ្លាំងក្លានូវតួនាទី និងការស្វះស្វែងរបស់ឯកឧត្តមអគ្គនាយកអង្គការពាណិជ្ជកម្មពិភពលោក ដើម្បីជំរុញការចរចារបៀបវារៈក្រុងដូហាឱ្យបានឿនលឿនទៅមុខ និងបញ្ចប់ឱ្យបានឆាប់រហ័ស និងប្រកបដោយជោគជ័យ ដែលវានឹងជាវិភាគទានយ៉ាងសំខាន់នៅក្នុងការអភិវឌ្ឍពាណិជ្ជកម្មរបស់ពិភពលោក ជាពិសេសប្រទេសអភិវឌ្ឍន៍តិចតួចតាមរយៈការបើកច្រកទីផ្សារទំនិញសេវាកម្ម ការពង្រឹង និងពង្រីកសហប្រតិបត្តិការអភិវឌ្ឍន៍ពាណិជ្ជកម្ម និងការផ្តល់ភាពអនុគ្រោះ មិនជាប់ពន្ធគយ និងមិនជាប់កូតា ជាពិសេសពីសហរដ្ឋអាមេរិកដល់ប្រទេសអភិវឌ្ឍន៍តិចតួច តាមការសន្យានៅទីក្រុងហុងកុងនាពេលកន្លងទៅ ដែលវានឹងចូលរួមឆ្លើយតបប្រកបដោយប្រសិទ្ធភាពចំពោះវិបត្តិសេដ្ឋកិច្ចពិភពលោកបច្ចុប្បន្ន។ ការពិភាក្សាបានបន្តអំពីបញ្ហាហិរញ្ញប្បទានពាណិជ្ជកម្ម និងជំនួយសំរាប់ពាណិជ្ជកម្មផងដែរ ដែលមានតួនាទីយ៉ាងសំខាន់ នៅក្នុងការជួយស្រោចស្រង់សេដ្ឋកិច្ចជាតិ ឱ្យងើបផុតពីវិបត្តិសេដ្ឋកិច្ចពិភពលោក។ ចំពោះបញ្ហានេះ ឯកឧត្តមបណ្ឌិត **ចម ប្រសិទ្ធ** បានយល់ស្របថា ការផ្តល់ហិរញ្ញប្បទានពាណិជ្ជកម្ម គឺជាកត្តាដ៏សំខាន់មួយទៀតសំរាប់ប្រទេសអភិវឌ្ឍន៍តិចតួច ដូចជាកម្ពុជា ដើម្បីទ្រទ្រង់ដល់អ្នកផលិត ជាពិសេស សហគ្រាសធុនតូច និងមធ្យម ដើម្បីមានឱកាសប្រកួតប្រជែង និងបង្កើនសង្វាក់ផលិតកម្មឱ្យបានខ្លាំងក្លាថែមទៀត។ ឯកឧត្តមបណ្ឌិតទេសរដ្ឋមន្ត្រីក៏បានយល់ស្របផងដែរ អំពីភាពចាំបាច់នៃសម្បទានសំរាប់ទ្រទ្រង់មូលដ្ឋានគ្រឹះសំរាប់នាំចេញ តាមរយៈការបង្កើតនូវស្ថាប័នហិរញ្ញប្បទានពាណិជ្ជកម្ម ដែលជាស្ថាប័ន អភិវឌ្ឍន៍មួយដូចជា ធនាគារនីហ័រណេ-អាហ័រណេ ជាដើម។ ដូច្នេះ ការរួមបញ្ចូលគ្នានូវប្រភពធនធានសំរាប់ ហិរញ្ញប្បទាន ពាណិជ្ជកម្ម រួមទាំងការផ្តល់ ជំនួយសំរាប់ពាណិជ្ជកម្ម គឺមានសារៈសំខាន់ណាស់ដើម្បីជួយសង្គ្រោះវិស័យហិរញ្ញវត្ថុ ឱ្យងើបផុតពីវិបត្តិ និងឆ្ពោះទៅរកភាពរីកដុះដាលឡើងវិញ ។

ជាទីបញ្ចប់ឯកឧត្តមទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជាបានសំដែងនូវអំណរគុណ ចំពោះឯកឧត្តម **ប៉ាស្កាល់ ឡាមី** អគ្គនាយកអង្គការពាណិជ្ជកម្មពិភពលោក ដែលបានអញ្ជើញមកប្រទេសកម្ពុជា ក៏ដូចជាការគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជានៅការអភិវឌ្ឍន៍វិស័យពាណិជ្ជកម្ម និងជូនពរឱ្យឯកឧត្តមអគ្គនាយកទទួលបាននូវជ័យជំនះ នៅក្នុងបេសកម្មរបស់ឯកឧត្តម ជាពិសេសនៅក្នុងដំណើរបំពេញទស្សនកិច្ចការងារនៅព្រះរាជាណាចក្រកម្ពុជា ។